# CCHR ស្នើដល់រដ្ឋាភិបាលឱ្យលើកកម្ពស់សេរីភាពពលរដ្ឋ

**ដោយ យ៉ង ចាន់តារា**

2024.11.27



*លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្រោមគម្រោងជំនួយរបស់ប្រទេសចិន សម្រាប់គម្រោងកែលំអបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារបរិក្ខារអប់រំនៅកម្ពុជានៅស្រុកកងមាស ខេត្តកំពង់ចាម នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៤។*

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) រកឃើញករណីរឹតត្បិត និងបញ្ហាប្រឈមជាច្រើនទាក់ទងនឹងការអនុវត្តសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាន។ អង្គការសិទ្ធិមនុស្សមួយនេះស្នើដល់រដ្ឋាភិបាលឱ្យលើកកម្ពស់សេរីភាពពលរដ្ឋ ដូចមានចែងក្នុងច្បាប់។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) រកឃើញថា មានអ្នកការពារសិទ្ធិមនុស្សយ៉ាងតិច ៥០ នាក់ និងអ្នកសារព័ត៌មានយ៉ាងតិច ១៧ នាក់ ប្រឈមនឹងវិធានការផ្លូវច្បាប់ ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃទី១ កញ្ញា ២០២៣ ដល់ថ្ងៃទី៣១ សីហា ២០២៤។ ការប្រឈមនឹងវិធានការផ្លូវច្បាប់នោះ មានជាអាទិ៍ ការកោះហៅ ការសួរចម្លើយ ការឃាត់ខ្លួន ការឃុំខ្លួន ការបង្ខំឱ្យចុះហត្ថលេខា ការចោទប្រកាន់ ការផ្តន្ទាទោស និងការតម្កល់ការផ្តន្ទាទោស។ នេះបើយោងតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាន ដែលមានកម្រាស់ ៦៧ទំព័រ ចេញផ្សាយកាលពីថ្ងៃទី២៦ វិច្ឆិកា។

អ្នកសម្របសម្រួលគម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជានៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) លោក ហួន ផន ថ្លែងថា សេរីភាពនៃការបញ្ចេញមតិ និងសារព័ត៌មាននៅកម្ពុជា មិនមានភាពល្អប្រសើរនោះទេ ដោយសារអ្នកសារព័ត៌មានបន្តរងការយាយី

ហើយអ្នកការពារសិទ្ធិមនុស្សក្នុងវិស័យមួយចំនួន ដូចជា ដីធ្លី បរិស្ថាន និងការងារ ជាដើម ត្រូវបានគេ យាយី តាមរយៈការចោទប្រកាន់ និងផ្តន្ទាទោសតាមផ្លូវតុលាការ។

លោក ហួន ផន៖ *«តាមរយៈការសាកសួរ និងសម្ភាសជាមួយអ្នកធ្វើការក្នុងវិស័យសិទ្ធិមនុស្សមួយ ចំនួន ទីមួយការងារដែលគាត់គិតថា បញ្ហាហ្នឹងជាបញ្ហារសើប គាត់ប្តូរមិនធ្វើលើបញ្ហាហ្នឹងទេ ប៉ុន្តែគាត់ ធ្វើលើបញ្ហាផ្សេងៗទៀតដែលគាត់គិតថា មិនរសើប ដើម្បីគាត់នៅអាចធ្វើការក្នុងវិស័យសិទ្ធិមនុស្សដ ដែល។ ហើយមានមួយចំនួនទៀតក៏គាត់បញ្ឈប់សកម្មភាពធ្វើការងារក្នុងវិស័យសិទ្ធិមនុស្ស ដោយ គាត់មានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន ការគំរាមកំហែង និងការយាយីតាមផ្លូវតុលាការជា ដើម» ។*

ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានេះ អ្នកការពារសិទ្ធិមនុស្សលេចធ្លោ ដែលរងការផ្តន្ទាទោសនោះ រួមមាន លោក ជា ចាន់ ប្រធានសហជីពមូលដ្ឋាននៅខេត្តកំពង់ស្ពឺនៃសហ ព័ន្ធសហជីពកម្ពុជា (CATU) និងកញ្ញា ឈឹម ស៊ីថរ ប្រធានសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្ម ករខ្មែរនៃក្រុមហ៊ុនកាស៊ីណូណាហ្គាវើលដ៍។ លោក ជា ចាន់ ត្រូវបានផ្តន្ទាទោសដោយតុលាការខេត្ត កំពង់ស្ពឺ តែក្រោយមកត្រូវបានលើកលែងការចោទប្រកាន់ដោយសាលាឧទ្ធរណ៍ភ្នំពេញ ខណៈ កញ្ញា ឈឹម ស៊ីថរ តុលាការបានតម្កល់សាលក្រមផ្តន្ទាទោស ហើយកញ្ញាត្រូវជាប់គុករយៈពេល ២ ឆ្នាំពេញ តាមអំណាចសាលក្រមរបស់តុលាការ។

របាយការណ៍ដដែលកត់ត្រាទៀតថា មានអ្នកសារព័ត៌មានក្នុងស្រុកចំនួន ៣នាក់ ទទួលរងការផ្តន្ទា ទោស ហើយអាជ្ញាធរបានដកហូតអាជ្ញាប័ណ្ណសារព័ត៌មានចំនួន ៣ស្ថាប័ន។ មជ្ឈមណ្ឌលសិទ្ធិមនុស្ស កម្ពុជាឱ្យដឹងទៀតថា ការយាយីឥតឈប់ឈរនេះ បានធ្វើឱ្យមានការរីករាលដាលនៃការដាក់កំហិតលើ ខ្លួនឯងក្នុងចំណោមអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ខណៈការទទួលបានព័ត៌មានពីមន្ត្រី សាធារណៈនៅតែមានបញ្ហាប្រឈម ហើយច្បាប់សិទ្ធិទទួលបានព័ត៌មាននៅតែមិនទាន់មាន។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលលោក ប៉ែន បូណា និងអ្នកនាំ ពាក្យគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាលលោក ស្រ៊ាង ចិន្តា ដើម្បីឆ្លើយតបរឿងនេះបានទេ កាលពីយប់ថ្ងៃទី ២៦ វិច្ឆិកា ដោយទូរស័ព្ទចូល តែពុំមានអ្នកទទួល។

ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សនេះ កាលពីខែឧសភា កន្លងទៅ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបាន ធ្វើសន្និសីទសារព័ត៌មានបង្ហាញពីរបាយការណ៍សង្ខេបស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាសម្រាប់ ដើមឆ្នាំ ២០២៤។ ក្នុងសន្និសីទនោះ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា លោក កែវ រ៉េមី បាន ថ្លែងការពាររដ្ឋាភិបាលថា សម្រេចបានសមិទ្ធផលធំលើគ្រប់វិស័យ ជាពិសេសក្នុងការអនុវត្តលទ្ធិប្រជា ធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ។

លោក កែវ រ៉េមី៖ *«រឿងការខ្វែងគំនិតគ្នា រវាងអ្នករាយការណ៍ ឬធ្វើកិច្ចការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ សហភាពអឺរ៉ុប ទៅលើសិទ្ធិមនុស្ស ខ្វែងគំនិតគ្នាជាមួយយើង គឺនៅត្រង់ទាក់ទងនឹងរឿងនយោបាយទេ និយាយឱ្យមែនទែន។ លំហប្រជាធិបតេយ្យគឺគណបក្សប្រឆាំង។ ខ្ញុំសូមជម្រាបជូនថា គឺយើងកុំឈ្លោះជាមួយបងប្អូនជនបរទេស ដែលធ្វើកិច្ចការរឿងសិទ្ធិមនុស្ស ឬក៏ជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិ។ ទាក់ទងទៅនឹងការងារសិទ្ធិមនុស្ស ស្អីក៏លើកបានដែរ ក៏ប៉ុន្តែការគ្រប់គ្រងសង្គម គឺខុសគ្នា»*។

ផ្ទុយពីការបកស្រាយនេះ អង្គការជាតិ និងអន្តរជាតិ ព្រមទាំងក្រុមអ្នកជំនាញសិទ្ធិមនុស្សអង្គការសហប្រជាជាតិផង បានចេញរបាយការណ៍ជាបន្តបន្ទាប់អំពីការធ្លាក់ចុះនៃការគោរពសិទ្ធិមនុស្ស និងការរំលោភលើសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋខ្មែរ ប្រព្រឹត្តដោយអាជ្ញាធររដ្ឋាភិបាល។ ការរំលោភបំពានទាំងនោះមានលក្ខណៈធ្ងន់ធ្ងរ និងជាប្រព័ន្ធ។

អនុប្រធានផ្នែកសិទ្ធិមនុស្ស ដីធ្លី និងធនធានធម្មជាតិនៃសមាគមអាដហុក (ADHOC) លោក យិន ម៉េងលី ថ្លែងថា របាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សឆ្លុះបញ្ចាំងការពិត និងមានលក្ខណៈដូចគ្នាទៅនឹងរបាយការណ៍របស់អង្គការសិទ្ធិមនុស្សផ្សេងទៀត។

លោក យិន ម៉េងលី៖ *«ក្នុងប្រទេសប្រជាធិបតេយ្យ ប្រទេសជឿនលឿន គេអត់ដែលយកអ្វីដែលប្រជាពលរដ្ឋនិយាយ អ្វីដែលប្រជាពលរដ្ឋបញ្ចេញមតិដើម្បីស្ថាបនាដល់រដ្ឋាភិបាលទៅជាការខុស ឬចោទប្រកាន់នោះទេ»* ។

ក្នុងដំណើរបេសកកម្មស្វែងរកការពិតនៅកម្ពុជា កាលពីខែមិថុនា កន្លងទៅ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក វិទិត មុនតាប៊ិន (Vitit Muntarbhorn) បានកត់សម្គាល់ពីបញ្ហាជាច្រើនពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស ប្រព្រឹត្តដោយរដ្ឋាភិបាលថ្មីរបស់លោក ហ៊ុន ម៉ាណែត។ ក្នុងនោះ ការរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាលមានលក្ខណៈកាន់តែធ្ងន់ធ្ងរ បើស្ថាប័នទាំងនោះត្រូវបានគេមើលឃើញថា មានទស្សនៈផ្ទុយពីក្រុមអ្នកដឹកនាំបក្សកាន់អំណាច។

ក្រោមការគ្រប់គ្រងរយៈពេលជាង ១ឆ្នាំរបស់លោក ហ៊ុន ម៉ាណែត អាជ្ញាធរបានចាប់ខ្លួនសកម្មជននយោបាយ សមាជិកសង្គមស៊ីវិល សកម្មជន និងអ្នកបញ្ចេញមតិរិះគន់រដ្ឋាភិបាលលើសពី ១០០នាក់ ក្នុងនោះមនុស្សចំនួន ៨៣ នាក់ កំពុងជាប់ឃុំក្នុងពន្ធនាគារ ដោយសារតែការអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួន។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្នើដល់រដ្ឋាភិបាល ឱ្យមានចំណាត់ការជាក់លាក់ក្នុងការការពារ និងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ ដើម្បីធានាថា ពលរដ្ឋអាចបញ្ចេញទស្សនៈយល់ឃើញដោយមិនមានការភ័យខ្លាចចំពោះការសងសឹក៕